តុលាការកំពូល

លេខ ០៧/២៤/តកចសត

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ប្រធានតុលាការកំពូល

**ជម្រាបមក**

## លោកព្រះរាជអាជ្ញា អមតុលាការក្រុងភ្នំពេញ

**កម្មវត្ថុ:** អំពីការធ្វើអាជីវកម្មគ្មានការអនុញ្ញាតបម្រើសេវាទូរស័ព្ទទៅក្រៅប្រទេស តាមប្រព័ន្ធអ៊ីនធឺណែត ។

**យោង:** លិខិតលេខ ៣៨.ព្រទ-០៤ ចុះថ្ងៃទី២៩-០១-០៤ របស់អយ្យការ អមតុលាការក្រុងភ្នំពេញ ។

-មតិសម្រេចរបស់អង្គប្រជុំ តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល នាថ្ងៃទី២៥-០១-០៤ ។

តុលាការកំពូល សូមជម្រាបលោកព្រះរាជអាជ្ញាថា កាលពីថ្ងៃទី២៥-០២-០៤ តុលាការកំពូល និងមហាអយ្យការ អមតុលាការកំពូល បានបើកសម័យប្រជុំមួយ ដើម្បីពិភាក្សាលើសំណើរបស់លោកដែលបានស្នើសុំមតិណែនាំដូចក្នុងកម្មវត្ថុខាងលើ ។ អង្គប្រជុំបានសម្រេចថា

១-ច្បាប់ស្តីពីវិស័យប្រៃសណីយ៍ ពុំបានចែងឱ្យផ្តន្ទាទោសអំពីបទល្មើស ការធ្វើអាជីវកម្មគ្មានការអនុញ្ញាត្តិបម្រើសេវាទូរស័ព្ទទៅក្រៅប្រទេសតាមប្រព័ន្ធអ៊ីនធឺណែតទេ ។ សារាចរប្រកាស និងសេចក្តីជូនដំណឹងរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក៏ពុំអាចយកទៅចោទប្រកាន់ និងផ្តន្ទាទោសជនល្មើសបានដែរ ។ ដូច្នេះដើម្បីផ្តន្ទាទោសបទល្មើស បម្រើសេវាទូរស័ព្ទដូចខាងលើក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ត្រូវតែធ្វើច្បាប់មួយឱ្យច្បាស់សម្រាប់វិស័យនេះ ។

២-តាមគោលការណ៍ច្បាប់ព្រហ្មទណ្ឌស្តីពីបទល្មើសចោរកម្ម ដែលមានចែងក្នុងមាត្រា៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល គឺសំដៅតែលើទ្រព្យសម្បត្តិ ដែលមានរូបរាងអាចចាប់ ឬកាន់ ឬអាចផ្លាស់ប្តូរទីកន្លែងបានដែលជនល្មើសបានយកចលវត្ថុទាំងនោះមកធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន ។ រីឯការធ្វើអាជីវកម្មដែលគ្មានការអនុញ្ញាត្តិនូវសេវាទូរស័ព្ទតាមប្រព័ន្ធអ៊ីនធឺណែត ពុំអាចធ្វើការចោទប្រកាន់តាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលបានទេ ។ ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសនីតិរដ្ឋគេពុំអាចយកបទល្មើស ដែលពុំមានច្បាប់ចែងទៅផ្តន្ទាទោសតាមមាត្រាណាមួយ ដែលគេសន្មត់ថា ប្រហាក់ប្រហែលនោះទេ ។

៣-ក្នុងពេលដែលពុំទាន់មានច្បាប់សម្រាប់ផ្តន្ទាទោសជនល្មើសពីបទខាងលើនេះក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានសិទ្ធិអនុវត្តវិធានការណ៍រដ្ឋបាលដោយបិទការធ្វើអាជីវកម្មជាស្ថាពរ និងប្តឹងទៅតុលាការរដ្ឋប្បវេណី ដើម្បីទាមទារសំណងអន្តរាយ និងជម្ងឺចិត្តតាមក្រឹត្យច្បាប់ លេខ ៨.ក្រ.ច ចុះថ្ងៃទី២៨-១០-១៩៨៤ ។

សូមលោកព្រះរាជអាជ្ញា ទទួលនូវការរាប់អានពីខ្ញុំ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៤

**ឌិត មុន្ទី**

ចម្លងជូន

-ក្រសួងយុត្តិធម៌

-សាលាឧទ្ធរណ៍

-តុលាការ និងអយ្យការខេត្ត-ក្រុង

-ឯកសារ